អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-May-22, 13:21
CMS/CFO: Sann Rada

# អនុស្សរណៈអន្តរការិយាល័យ

**ផ្ញើជូន៖** ប្រធានអង្គជំនុំជម្រះតុលាការកំពូល

**ចម្លងជូន៖** លោក គង់ សូភី
ប្រធាន ផ្នែកគ្រប់គ្រងតុលាការ

**ពី៖** លោក កើត សុខា
មន្ត្រីគាំពារសាក្សី/អ្នកជំនាញ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ

**កាលបរិច្ឆេទ៖** ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២

**កម្មវត្ថុ៖** **អនុស្សរណៈរបស់ អ.ជ.ត.ក ស្តីពីគោលការណ៍ណែនាំអំពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ** (E71/1/1)

---

អង្គភាពគាំពារសាក្សី និងអ្នកជំនាញសូមថ្លែងអំណរគុណដែលមានឱកាសផ្តល់ជូនធាតុចូលស្តីពីដំណើរការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ក្នុងសំណុំរឿង ០០២។

ខ្ញុំបាទសូមភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ រួមទាំងការចេញវិធានការការពារនានា ដើម្បីឱ្យពួកគេមកផ្តល់សក្ខីកម្ម។

សូមមេត្តាកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឈ្មោះចំពោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ដែលបានផ្តល់សក្ខីកម្មជាសាធារណៈ នៅក្នុងសាលក្រមរបស់ខ្លួន (ឯកសារ E313, E465) និងនៅក្នុងសេចក្តីសម្រេចអំពីសាក្សី (ឯកសារ E312, E459)។ ហេតុនេះ ការប្រើប្រាស់រហស្សនាមត្រូវបានកម្រិតត្រឹមតែកិច្ចដំណើរការនីតិវិធីជំនុំជម្រះប៉ុណ្ណោះ។

តាមការយល់ដឹងរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ វិធានការពារផ្សេងទៀតដែលអង្គជំនុំជម្រះបានចេញ (ការបំប្លែងមុខ/សំឡេង) នៅមាននៅឡើយចំពោះសាក្សីដែលបានបង្ហាញអត្តសញ្ញាណ។

ខ្ញុំបាទសង្ឃឹមថា ព័ត៌មាននេះអាចជួយអង្គជំនុំជម្រះបាន។ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំបាទវិញ ក្នុងករណីដែលឯកឧត្តមប្រធានចង់ជ្រាបនូវព័ត៌មានបន្ថែមទៀត។

ឯកសារភ្ជាប់៖ បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ និង ០០២/០២។